# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០២-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៣៩៦ ស្តីពីការបង្កើតគណៈទន្តពេទ្យកម្ពុជា ៥៦៧៦

១៤-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៤១០ ស្តីពីការតែងតាំងឯកឧត្តមចំនួន ១៤ រូបជាទីប្រឹក្សា និង ឯកឧត្តមចំនួន ០៣ រូប ជាជំនួយការសម្តេចហេង សំរិន អនុប្រធានទី ១ រដ្ឋសភានីតិកាលទី ៣ ៥៦៨៨

១៤-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៤១១ ស្តីពីការតែងតាំង ឯកឧត្តម **អ៊ុំ ឆាយ** ជាឧកញ៉ា ៥៦៩០

១៤-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៤១២ ស្តីពី :

១-ការសំរួលភារកិច្ចឯកឧត្តម **ឡៃ ទីរៈ**

២-ការប្រគល់ភារកិច្ចជូនលោក **គុជ ម៉ូលី** ៥៦៩១

១៤-៩-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៩០៥/ ៤១៣ ស្តីពីការតែងតាំង ឯកឧត្តម **សាយ លាងសេង** ជាទីប្រឹក្សាសម្តេច **នរោត្តម សិរីវុឌ្ឍ** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៥៦៩៣


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


២០-៩-២០០៥ -អនុក្រឹត្យលេខ ៧៤០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ៥៦៩៤


## III-ការិយាល័យបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


១៥-៩-២០០៥ -ប្រកាសលេខ ៥៧៦ សហវ.ពដស្តីពី ការប្រមូលពន្ធអាករជាប្រាក់រៀល ៥៦៩៥


### ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់


២៣-៩-២០០៥ -សេចក្តីណែនាំលេខ ១៤៥៥ ដនស/គសជ ស្តីពី នីតិវិធីសវនាការ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ៥៦៩៧

## ៣.ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១២-៩-២០០៥ -លិខិតលេខ ២០២១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ស៊ី ស៊ី ហ្សេត ឆាយណា ស៊ីបភីង** ៥៧១០

១២-៩-២០០៥ -លិខិតលេខ ២០៤៩ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តកំពង់ធំ នៃព្រះរាជាណាចក្រកម្ពុជា ៥៧១២

០២-៩-២០០៥ -លិខិតលេខ ២០៥០ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តកំពង់ចាម នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៣

០២-៩-២០០៥ -លិខិតលេខ ២០៥១ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តបន្ទាយមានជ័យ នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៤

០២-៩-២០០៥ -លិខិតលេខ ២០៥២ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តសៀមរាប នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៥

០២-៩-២០០៥ -លិខិតលេខ ២០៥៣ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំក្រុងព្រះសីហនុ នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៦

០២-៩-២០០៥ -លិខិតលេខ ២០៥៤ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តបាត់ដំបង នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៧

០២-៩-២០០៥ -លិខិតលេខ ២០៥៥ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តស្វាយរៀង នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៨

០២-៩-២០០៥ -លិខិតលេខ ២០៥៦ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃ្វេសណេត**" ប្រចាំខេត្តពោធិសាត់ នៃព្រះរាជាណាចក្រកម្ពុជា ៥៧១៩

០២-៩-២០០៥ -លិខិតលេខ ២០៥៧ ពណ.នតក ស្តីពី ការអនុញ្ញាតជាគោលការណ៍ឱ្យបង្កើតការិយាល័យតំណាងពាណិជ្ជកម្មនៃក្រុមហ៊ុន "**ឃេសណោគ**" ប្រចាំខេត្តកំពត នៃព្រះរាជាណាចក្រកម្ពុជា ៥៧២០
០៥-៩-២០០៥ -លិខិតលេខ ២០៦១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ខេមបូ រេស៍ លីមីធីត** ៥៧២១
០៥-៩-២០០៥ -លិខិតលេខ ២០៦២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស៊ាន ស្តេសល ឡូតូ លីមីធីត** ៥៧២៣
០៥-៩-២០០៥ -លិខិតលេខ ២០៧៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ម៉ូខែន ទីហ៊ុយល គ្រេឌីង ខូ អិលធីឌី (អិម ទី ធី)** ៥៧២៥
០៦-៩-២០០៥ -លិខិតលេខ ២០៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អ៊ី.អិម.អឃីត ប៉ារីសស៊ីយ៉ែន** ៥៧២៧
០៧-៩-២០០៥ -លិខិតលេខ ២០៧៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អេស៊ា តេលេស** ៥៧២៩
០៧-៩-២០០៥ -លិខិតលេខ ២០៧៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ដុក ទ៊ូ (ខេមបូឌា)** ៥៧៣១
០៧-៩-២០០៥ -លិខិតលេខ ២០៨០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អូហ៍.អូ.យេស អ៊ិនធើណេសិនណាល** ៥៧៣៣
០៧-៩-២០០៥ -លិខិតលេខ ២០៨១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ណារីតា ម៉ូធ័រយ៉ៃរ (ខេមបូឌា)** ៥៧៣៥
០៧-៩-២០០៥ -លិខិតលេខ ២០៨២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **អិន អេស អេស ស៊ី ឌីវេឡុបមេន** ៥៧៣៧
០៧-៩-២០០៥ -លិខិតលេខ ២០៨៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **សំ សុខ (ខេមបូឌា) ខូ អិលធីឌី** ៥៧៣៩
០៧-៩-២០០៥ -លិខិតលេខ ២០៨៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឡាក់សាម៉ាន់ ខូ អិលធីឌី** ៥៧៤១
០៧-៩-២០០៥ -លិខិតលេខ ២០៨៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ណូវ៉ាឌី សាញ** ៥៧៤៣

០៧-៩-២០០៥ -លិខិតលេខ ២០៩០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**សេង វិបុល អ៊ីមផត អិចផត** ៩៧៤៥

០៧-៩-២០០៥ -លិខិតលេខ ២០៩១ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ឆួរ អ៊ិនធើប្រាយ សេនធ័រ (ខេមបូឌា)** ៩៧៤៧

០៧-៩-២០០៥ -លិខិតលេខ ២០៩២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ខាហ្គោ ម៉ាឃីធីង អ៊ិនធើត្រែន (ខេមបូឌា)** ៩៧៤៩

០៨-៩-២០០៥ -លិខិតលេខ ២០៩៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វីអិនស៊ី (ខេមបូឌា)** ៩៧៥១

០៨-៩-២០០៥ -លិខិតលេខ ២០៩៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ចេនឡា ឡូជីស្ទីក ខបភើរេសិន** ៩៧៥៣

០៨-៩-២០០៥ -លិខិតលេខ ២០៩៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**ស៊ីន ហា ម៉ាញូនីង ខូ អិលធីឌី** ៩៧៥៥

០៨-៩-២០០៥ -លិខិតលេខ ២០៩៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
**វីលលីម៊ិច** ៩៧៥៧

នស/រកត/០៩០៥/៣៩៦

# ព្រះរាជក្រឹត្យ
# ស្ដីពី
# ការបង្កើតគណៈឧន្តពេទ្យកម្ពុជា

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី នាថ្ងៃ២៩ ខែកក្កដា ឆ្នាំ២០០៥

## ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើតគណៈទន្តពេទ្យមួយ ដើម្បីប្រមូលផ្តុំទន្តពេទ្យទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាទន្តពេទ្យក្នុងព្រះរាជក្រឹត្យនេះគឺ នីតិជនដែលមានសញ្ញាប័ត្រទន្តសាស្ត្រចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជន និងកីឡា ឬសញ្ញាប័ត្រទន្តសាស្ត្រចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

ទន្តពេទ្យទាំងអស់ដែលប្រកបវិជ្ជាជីវៈទន្តសាស្ត្រ ត្រូវសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យ ។

## ជំពូកទី ២
## បេសកកម្មរបស់គណៈទន្តពេទ្យ

**មាត្រា ២.-**

គណៈទន្តពេទ្យ ត្រូវឃ្លាំមើលការប្រព្រឹត្តទៅនៃបណ្តាគោលការណ៍សីលធម៌ ភាពសុចរិតយុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រឱ្យបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈទន្តពេទ្យ ត្រូវឃ្លាំមើលការប្រតិបត្តិរបស់សមាជិកខ្លួនទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈព្រមទាំងបទប្បញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌ទន្តពេទ្យ ។

គណៈទន្តពេទ្យធានាការពារកិត្តិយស និងឥស្សរភាពរបស់វិជ្ជាជីវៈទន្តសាស្ត្រ ។

គណៈទន្តពេទ្យបំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង ក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ និងក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ។

## ផ្នែកទី ១
## តួនាទីសីលធម៌

**មាត្រា ៣.-**

គណៈទន្តពេទ្យមានបន្ទុករៀបរៀងក្រមសីលធម៌ទន្តពេទ្យ យកលំនាំតាមលក្ខណៈចាំបាច់នៃវិជ្ជាជីវៈ ក្នុងការវិវត្តន៍ខ្ជាប់ខ្ជួនខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ចដែលត្រូវធ្វើអោយវិវត្តន៍ល្អក្នុងផលប្រយោជន៍របស់អ្នកជម្ងឺ ។

គណៈទន្តពេទ្យតាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិបត្តិ ។

គណៈទន្តពេទ្យជាអង្គការស្វយ័តការចំណាយការផ្គត់ផ្គង់ប្រាក់កាស ម្ចាស់ការខ្លួនឯង ធានាឥស្សរភាព ការពារផលប្រយោជន៍សីលធម៌វិជ្ជាជីវៈ ។

## ផ្នែកទី ២
## តួនាទីគ្រប់គ្រងរដ្ឋបាល

**មាត្រា ៤.-**

ការចាត់ចែងអំណាចត្រូវអនុលោមតាមបញ្ជាគណៈទន្តពេទ្យ ។

គណៈទន្តពេទ្យត្រូវរៀបចំធ្វើ និងថែរក្សាទុកជាប្រចាំនូវបញ្ជីរាយនាមទន្តពេទ្យដែលបានចុះឈ្មោះបំពេញល័ក្ខខ័ណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ចនៃការចុះឈ្មោះ ក្នុងបញ្ជីរាយនាមទន្តពេទ្យ គឺដើម្បីបំពេញការរៀបចំថៃទាំព្យាបាលជម្ងឺ ។

គណៈទន្តពេទ្យជាអង្គការវិជ្ជាជីវៈតែមួយគត់ ដែលមានមុខងារតាមឃ្លាំមើលល័ក្ខខ័ណ្ឌនៃការប្រកបវិជ្ជាជីវៈទន្តពេទ្យនេះ ។

## ផ្នែកទី ៣
## តួនាទីសម្រេចសេចក្តីតាមបែបតុលាការ

**មាត្រា ៥.-**

បណ្តឹងអំពីការប្រព្រឹត្តខុសឆ្គងនៃមុខវិជ្ជាជីវៈរបស់ទន្តពេទ្យណាមួយទៅគណៈទន្តពេទ្យ មិនមែនជាឧបសគ្គក្នុងការធ្វើបណ្តឹងចំពោះការប្រព្រឹត្តខុសឆ្គងនេះ ទៅតុលាការឡើយ ។

## ផ្នែកទី ៤
## តួនាទីពិភាក្សាផ្តល់យោបល់

**មាត្រា ៦.-**

គណៈទន្តពេទ្យអាចត្រូវបានកោះហៅអោយផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធនឹងវិជ្ជាជីវៈទន្តពេទ្យទាំងឡាយ ។

## ផ្នែកទី ៥
## តួនាទីជួយសង្គ្រោះគ្នាទៅវិញទៅមក

**មាត្រា ៧.–**

ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់ទន្តពេទ្យ និងគ្រួសារទន្តពេទ្យ ។

ការជួយសង្គ្រោះគ្នាបានរៀបចំតាមបែបបទដូចតទៅ ÷

-ក្រុមប្រឹក្សាគណៈទន្តពេទ្យកម្ពុជាត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បម្រុងសម្រាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតអោយប្រើប្រាស់ប្រាក់បម្រុងជាជំនួយភ្លាមៗ ក្នុងករណីសមរម្យដល់គ្រួសារទន្តពេទ្យដែលត្រូវរងទុក្ខលំបាក ។

-ក្រុមប្រឹក្សានេះត្រូវមានគណៈកម្មការមួយជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគមទន្តពេទ្យកម្ពុជាម្នាក់ជាសមាជិក ។

-គណៈកម្មការនេះ ចាត់ចែងអោយមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីទន្តពេទ្យម្នាក់ៗដែលចុះឈ្មោះ ក្នុងគណៈទន្តពេទ្យ ។

## ជំពូកទី ៣
## រចនាសម្ព័ន្ធ
## ផ្នែកទី ១
## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ខេត្ត ក្រុង

**មាត្រា ៨.–**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ខេត្ត ក្រុងដែលសរសេរកាត់ថា ក.ទ.ខ.ត្រូវបង្កើតនៅតាមខេត្ត ក្រុងនីមួយៗនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត ក្រុង ដែលមានចំនួនទន្តពេទ្យតិចជាងដប់ (១០)នាក់ ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេដើម្បីបង្កើតក្រុមប្រឹក្សាគណៈទន្តពេទ្យ ។

**មាត្រា ៩.–**

ក.ទ.ខ. ត្រូវមានសមាជិកពេញសិទ្ធិចំនួនបី(០៣)រូប និងសមាជិកជំនួសចំនួនបី(០៣)រូប ក្នុងករណីដែលចំនួនទន្តពេទ្យដែលបានចុះឈ្មោះក្នុងបញ្ជីមានមិនលើសពីសាមសិប (៣០)នាក់ ។ ចំនួននេះនឹងឡើងទៅដល់ប្រាំ, ប្រាំបួន, ដប់មួយ, ដប់ប្រាំ, ដប់ប្រាំបួន, ម្ភៃមួយរូប បើសិនជាចំនួនទន្តពេទ្យនៅក្នុងបញ្ជីមានលើសពីសាមសិប, ហាសិប, មួយរយ, ប្រាំរយ, មួយពាន់, ពីរពាន់នាក់ ។

**មាត្រា ១០.–**

ក.ទ.ខ. ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយបណ្តាទន្តពេទ្យដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់ ក.ទ.ខ. សម្រាប់រយៈពេលប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិ អាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសរើសសារជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេលពីរ (០២) ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន១/៣ នៃសមាជិករបស់ក្រុមប្រឹក្សា ។ ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុង ក្នុងករណីដែលចំនួនសមាជិកផ្លាស់ប្តូរមានចំនួនចែកមិនដាច់ ។

ការិយាល័យរបស់ គ.ទ.ខ. រួមមាន ប្រធានក្រុមប្រឹក្សាមួយរូប អនុប្រធានមួយរូប លេខាធិការមួយរូប ហិរញ្ញិកមួយរូប និងសមាជិកមួយរូប ។

**មាត្រា ១១.-**

គ.ទ.ខ. បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត ក្រុងរបស់ខ្លួន និងក្រោមការត្រួតពិនិត្យរបស់គណៈទន្តពេទ្យជាតិចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។ គ.ទ.ខ. សម្រេចអារកាត់ក្នុងការចុះឈ្មោះទន្តពេទ្យដែលបានបំពេញល័ក្ខខ័ណ្ឌតាមមាត្រា៣ ជំពូកទី១ មាត្រា៦ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ ជំនួយវេជ្ជសាស្ត្រ នៅក្នុងបញ្ជីរបស់គណៈទន្តពេទ្យ ។ គ.ទ.ខ. មិនប្រកាន់ភេទ ជំនឿសាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

**មាត្រា ១២.-**

គ.ទ.ខ. ពុំមានអំណាចដាក់វិន័យទេ បើមានពាក្យបណ្តឹងចំពោះទន្តពេទ្យដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន គ.ទ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈទន្តពេទ្យភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

**មាត្រា ១៣.-**

ប្រធានតំណាងឱ្យ គ.ទ.ខ. នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

**មាត្រា ១៤.-**

ការប្រជុំនៃក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។ កាលណាមានសម្លេងស្មើគ្នា សម្លេងរបស់ប្រធានមានឧត្តមានុភាពសម្រេច ។ ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសម្លេងពិគ្រោះយោបល់ ។ គ.ទ.ខ. អាចអញ្ជើញទីប្រឹក្សាច្បាប់មួយរូបចូលរួមក្នុងអង្គប្រជុំ ។

**មាត្រា ១៥.-**

ទន្តពេទ្យប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅតាមបណ្តាខេត្ត ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំដោយក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុងពាក់ព័ន្ធ ។ អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យតែចំពោះទន្តពេទ្យដែលមានសញ្ញាប័ត្រទន្តសាស្ត្រចេញដោយក្រសួងសុខាភិបាល ឬក្រសួងអប់រំយុវជន និងកីឡា ឬសញ្ញាប័ត្រ

ចេញដោយគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ក្នុងការប្រកបវិជ្ជាជីវៈទន្តសាស្ត្រ និងបានបំពេញល័ក្ខខ័ណ្ឌច្បាប់ និងក្រមសីលធម៌ដែលបានកំណត់ ។

ទន្តពេទ្យអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត ក្រុង ដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦.-**

ក.ទ.ខ. ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរបី (០៣)ខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅទន្តពេទ្យសាមី ។ បើមានការបដិសេធសេចក្តីសម្រេចត្រូវមានមូលហេតុច្បាស់លាស់ ។

ការអនុញ្ញាតឱ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យខេត្ត ក្រុងនីមួយៗ ត្រូវជូនដំណឹងយ៉ាងឆាប់បំផុតទៅអាជ្ញាធរខេត្ត ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត ក្រុងពាក់ព័ន្ធ និងទៅក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ។

**មាត្រា ១៧.-**

ក្រោយពីបានការអនុញ្ញាតអោយចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យខេត្ត ក្រុង ដែលខ្លួនរស់នៅហើយ ទន្តពេទ្យអាចប្រកបវិជ្ជាជីវៈទន្តសាស្ត្រនៅខេត្ត ក្រុង ដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។ ក្នុងករណីមានការផ្លាស់ប្តូរលំនៅស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត ក្រុង ដែលខ្លួនបានសុំចុះឈ្មោះទន្តពេទ្យ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសារជាថ្មី ទៅក្រុមប្រឹក្សាខេត្ត ក្រុង ដែលខ្លួនទៅរស់នៅ ។

**មាត្រា ១៨.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យខេត្ត ក្រុង ត្រូវទទួលបណ្តឹងជំទាស់ពីក្រុមប្រឹក្សាជាតិ សមាគមទន្តពេទ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការ ឬទន្តពេទ្យណាម្នាក់ ដែលបានចុះឈ្មោះនៅក្នុង បញ្ជីគណៈទន្តពេទ្យ រួចហើយធ្វើរបាយការណ៍ផ្ញើជូនគណៈទន្តពេទ្យជាតិ ។

## ផ្នែកទី ២
## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ភូមិភាគ

**មាត្រា ១៩.-**

ការបែងចែកភូមិភាគសម្រាប់គណៈទន្តពេទ្យកម្ពុជានេះ ត្រូវបានរៀបចំដូចខាងក្រោម ៖

ភូមិភាគ ១ : រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។

ភូមិភាគ ២ : មានខេត្តពោធិសាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។

ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត ។

ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។

ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង និងស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

**មាត្រា ២០.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ភូមិភាគសរសេរកាត់ថា គ.ទ.ភ. មានតួនាទីជាក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋមមានសមាជិកពេញសិទ្ធិចំនួនប្រាំ (០៥)រូប និងសមាជិកជំនួសចំនួនប្រាំ (០៥)រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម គ.ទ.ខ. ក្នុងភូមិភាគ ។ គ.ទ.ខ. នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឱ្យបានយ៉ាងតិចមួយរូបពេញសិទ្ធិ និងមួយរូប ជាជំនួយ ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅខេត្ត ក្រុង ដោយផ្អែកទៅលើចំនួនទន្តពេទ្យ ដែលបានចុះឈ្មោះ ជាសមាជិកក្រុមប្រឹក្សាភូមិភាគ ។ សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោត ជ្រើសរើសសម្រាប់រយៈពេល ប្រាំមួយ (០៦)ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួន នៅក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួយត្រូវចូលជំនួសសមាជិកពេញសិទ្ធិ នៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

**មាត្រា ២១.-**

ប្រធាន គ.ទ.ភ. ប្រធាន គ.ទ.ខ. និងអគ្គលេខាធិការនៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

**មាត្រា ២២.-**

អង្គប្រជុំ គ.ទ.ភ. ត្រូវបានចូលរួមក្នុងឋានៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ ៖

- តំណាងឱ្យរដ្ឋមន្ត្រីក្រសួងសុខាភិបាល ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល
- ប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគ
- ទីប្រឹក្សាច្បាប់មួយរូប ចាត់តាំងដោយប្រធានតុលាការនៃខេត្ត ក្រុង នោះ
- ទន្តពេទ្យការងារមួយរូបបើមាន ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រភូមិភាគ ។

**មាត្រា ២៣.-**

នៅក្នុងក្របខ័ណ្ឌគណៈទន្តពេទ្យ គ.ទ.ភ. អនុវត្តការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

ក.ទ.ភ. អាចទទួលពាក្យបណ្តឹងជំទាស់ពី ក.ទ.ជ. ក.ទ.ខ. សមាគមទន្តពេទ្យ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានមន្ទីរសុខាភិបាល អាជ្ញាធរខេត្ត ក្រុង ព្រះរាជអាជ្ញាអមតុលាការខេត្ត ក្រុង ឬសាមីទន្តពេទ្យ ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យ ។

ក.ទ.ភ. ត្រូវពិនិត្យសម្រេចនៅក្នុងរយៈពេលប្រាំមួយ (០៦) ខែយ៉ាងយូរ ក្រោយបានទទួលពាក្យបណ្តឹង ។ បើមិនដូច្នេះទេ កទ.ជ. អាចបញ្ជូនពាក្យបណ្តឹងនេះទៅ ក.ទ.ភ. ណាមួយផ្សេងទៀតដែលបានជ្រើសរើស ។

**មាត្រា ២៤.-**

ទន្តពេទ្យដែលកំពុងបម្រើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈទន្តពេទ្យនឹងអាចអញ្ជើញមកបកស្រាយនៅចំពោះមុខ ក.ទ.ភ. បាន ចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួនតែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង ឬតាមរយៈព្រះរាជអាជ្ញាអមតុលាការតែប៉ុណ្ណោះ ។

**មាត្រា ២៥.-**

ការដាក់ទោសវិន័យត្រូវធ្វើឡើងនៅចំពោះមុខ ទន្តពេទ្យសាមីត្រូវតែមានអ្នកការពារដែលជាទន្តពេទ្យ ឬជាមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២៦.-**

ក.ទ.ភ. ត្រូវមានបញ្ជីកត់ត្រាការជំនុំជម្រះកាត់សេចក្តីនៅរាល់សវនាការនីមួយៗ ។ គេត្រូវធ្វើកំណត់ហេតុត្រឹមត្រូវដោយមានការបញ្ជាក់ និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវគេចោទសួរនោះផង ។

**មាត្រា ២៧.-**

ក.ទ.ភ. ដោយមានការចូលរួមពីផ្នែកវិន័យនៃ ក.ទ.ជ អាចដាក់វិន័យដូចខាងក្រោម ÷

១- ការព្រមាន ។

២- សេចក្តីបន្ទោសដោយកត់ទុកក្នុងឯកសារផ្ទាល់ខ្លួន ។

៣- ហាមប្រកបវិជ្ជាជីវៈ មួយរយៈពេលមិនលើសពីបី (០៣) ឆ្នាំ ឬជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារ ទន្តសាស្ត្រដែលរដ្ឋទទួលស្គាល់ ។

៤- ការលុបឈ្មោះចេញពីបញ្ជីគណៈទន្តពេទ្យ ។

ទន្តពេទ្យដែលបានទទួលវិន័យត្រូវបាត់សមាជិកភាពនៅក្នុង ក.ទ.ខ. ក.ទ.ភ. ក.ទ.ជ. ក្នុងរយៈពេលមួយ (០១) ដល់បី (០៣) ឆ្នាំ ចំពោះវិន័យថ្នាក់ទីមួយ (០១) និងទីពីរ (០២) និងបាត់បង់ជាអចិន្ត្រៃយ៍ចំពោះវិន័យថ្នាក់ទីបី (០៣) និងទីបួន (០៤) ។

ទន្តពេទ្យដែលត្រូវលុបឈ្មោះពីបញ្ជី មិនអាចសុំចុះឈ្មោះនៅកន្លែងណាបានឡើយ ។

សេចក្តីដែលបានសម្រេចចុងក្រោយដែលបានលើកឡើងត្រូវតែផ្សព្វផ្សាយនៅគ្រប់ ក.ទ.ខ. ព្រមទាំងទៅ ក.ទ.ជ. ។ ការសម្រេចរបស់ ក.ទ.ក. ត្រូវតែមានហេតុផលច្បាស់លាស់ ។

**មាត្រា ២៨.-**

ក្រោយបានទទួលការលុបឈ្មោះចេញពីបញ្ជីអស់រយៈកាលបី (០៣) ឆ្នាំយ៉ាងតិចមក ទន្តពេទ្យពាក់ព័ន្ធអាចទទួលការលើកលែងវិន័យអំពីក្រុមប្រឹក្សាគណៈទន្តពេទ្យដែលបានដាក់វិន័យដល់ខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយទន្តពេទ្យសាមី ។ កាលណាលិខិតស្នើសុំលើកលែងវិន័យនេះត្រូវបានបដិសេធក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជម្រៅមក ការស្នើសុំលើកលែងវិន័យសារជាថ្មីនឹងអាចធ្វើទៅបានតែក្នុងរយៈកាលមួយឆ្នាំទៅមុខទៀត ។

**មាត្រា ២៩.-**

ការអនុវត្តន៍វិន័យរបស់ទន្តពេទ្យ មិនមែនជាឧបសគ្គរាំងដល់ការអនុវត្តន៍ការដាក់វិន័យ ចំពោះអំពើខុសឆ្គងដូចខាងក្រោមនេះឡើយ÷

១-ការចោទប្រកាន់ដែលរដ្ឋអំណាចសាធារណៈ ឬឯកជនអាចប្តឹងចំពោះតុលាការពីបទរដ្ឋប្បវេណី ។

២- សកម្មភាពស៊ីវិល ដើម្បីជូសជុលសងជម្ងឺចិត្ត ពីបទល្មើសថ្នាក់មជ្ឈឹម ។

៣- ការដាក់វិន័យផ្នែករដ្ឋបាល នៅកន្លែងធ្វើការរបស់ទន្តពេទ្យ ។

៤- អំពើខុសឆ្គងដែលទន្តពេទ្យបានប្រព្រឹត្តដោយរំលោភបំពាន ក្នុងការចូលរួមថែទាំទន្តសាស្ត្រដែលបានគ្រោងនៅច្បាប់សង្គម ។

## ផ្នែកទី ៣
## ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ជាតិ

**មាត្រា ៣០.-**

ក្រុមប្រឹក្សាគណៈទន្តពេទ្យថ្នាក់ជាតិសរសេរកាត់ថា ក.ទ.ជ. ត្រូវបានជ្រើសរើសដោយបោះឆ្នោតសម្រាប់រយៈពេលប្រាំមួយ (០៦) ឆ្នាំ បែងចែកដូចខាងក្រោម÷

-តំណាងអោយខេត្ត ក្រុង នីមួយៗចំនួនមួយ (០១) រូប ចាត់តាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង

-តំណាងអោយរាជធានីភ្នំពេញចំនួនពីរ (០២) រូប ចាត់តាំងដោយប្រធានមន្ទីរសុខាភិបាលរាជធានី ភ្នំពេញ

-តំណាងអង្គភាពថ្នាក់កណ្តាលចំនួនប្រាំ (០៥) រូប ចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល

-តំណាងអោយសកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាលចំនួនមួយ (០១) រូប ជ្រើសរើសដោយសហភាគរះរបស់គេ ។

**មាត្រា ៣១.-**

ក.ទ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួនមួយភាគបី(១/៣) ក្នុងរយៈពេលពីរ (០២)ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរ សមាជិកមួយភាគបី (១/៣)ម្តងៗ ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិ ត្រូវធ្វើការជ្រើសរើស ប្រធាន និងការិយាល័យរបស់ខ្លួនសម្រាប់ ពីរ (០២)ឆ្នាំ ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈទន្តពេទ្យជាតិកម្ពុជារួមមាន : ប្រធានក្រុមប្រឹក្សាមួយ (០១)រូប អនុប្រធានចំនួនពីរ (០២)រូប អគ្គលេខាធិការមួយ (០១)រូប អគ្គលេខាធិការរងមួយ (០១)រូប ហិរញ្ញិកមួយ (០១) រូប និងហិរញ្ញិករងមួយ (០១)រូប ។ ប្រធាន និងសមាជិក ក.ទ.ជ. ដែលចេញពីតំណែងអាចឈរឈ្មោះអោយគេជ្រើសរើសសារជាថ្មីបាន ។

**មាត្រា ៣២.-**

ក.ទ.ជ. មានជំនួយការជាទន្តពេទ្យចំនួនពីរ (០២)រូប តំណាងអោយរដ្ឋមន្ត្រីក្រសួងសុខាភិបាលមួយ (០១) រូប និងតំណាងអោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមួយ (០១)រូប ក្នុងឋានៈជាអនុប្រធាន និងមានសម្លេងពិគ្រោះយោបល់ ។

**មាត្រា ៣៣.-**

ក.ទ.ជ. មានផ្នែកវិន័យត្រូវមានសមាជិកប្រាំ (០៥)រូប ដឹកនាំដោយប្រធានមួយ (០១)រូប ជ្រើសតាំងក្នុងចំណោមសមាជិកប្រាំពីរ (០៧)រូបនេះ ។

**មាត្រា ៣៤.-**

បន្ទាប់ពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣ របស់ខ្លួន ក.ទ.ជ. ត្រូវធ្វើការបោះឆ្នោតជ្រើសរើសផ្នែកវិន័យសារជាថ្មី ។

**មាត្រា ៣៥.-**

ក.ទ.ជ. បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួនពេលបេសកកម្មដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។

ក.ទ.ជ.ឃ្លាំមើលជាអាទិ៍ការគោរពអនុវត្តតាម របស់សមាជិកនៃគណៈទន្តពេទ្យទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌ទន្តពេទ្យ ។

ក.ទ.ជ. សហការជាមួយ ក.ទ.ខ. ធ្វើការសិក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់ទន្តពេទ្យ ។

ក.ទ.ជ. បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួន និងពិនិត្យសិក្សានូវបណ្តាបញ្ហា ឬគម្រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៦.-**

ក.ទ.ជ. ត្រូវកំណត់អំពីចំនួនទឹកប្រាក់ វិភាគទានឯកភាពមួយ ដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

ក.ទ.ជ. ត្រូវកម្រិតផងដែរនូវចំនួនវិភាគទានដែល ក.ទ.ខ. ត្រូវបង់ជូនទៅ ក.ទ.ជ. ទៅ ក.ទ.ភ. នឹងត្រូវរក្សាទុកនៅក្នុង ក.ទ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទាន គឺជាកាតព្វកិច្ចរបស់សមាជិកម្នាក់ៗ ។ ក.ទ.ជ. គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈទន្តពេទ្យ និងអាចបង្កើត ឬឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈទន្តសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

ក.ទ.ជ. ត្រួតពិនិត្យការគ្រប់គ្រងរបស់ ក.ទ.ខ. និងក.ទ.ភ. ។ ក.ទ.ខ. ត្រូវរាយការណ៍ជូន ក.ទ.ជ. ជាមុនចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៧.-**

ក.ទ.ជ. ត្រូវបង្កើតគណៈកម្មការមួយ សម្រាប់ចាត់ចែងហិរញ្ញវត្ថុ និងធ្វើសវនកម្មផ្ទៃក្នុង ។ សមាជិកនៃគណៈកម្មការនេះត្រូវជ្រើសរើសដោយ ក.ទ.ជ.ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យនៃក្រុមប្រឹក្សា ។

ក្នុងដំណាច់ឆ្នាំនិមួយៗ គណៈកម្មការនេះ ត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន ក.ទ.ជ. ។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**មាត្រា ៣៨.-**

ក្នុងកំឡុងពេលប្រាំមួយ (០៦)ឆ្នាំដំបូង នៃអាណត្តិទី១សមាសភាពការិយាល័យរបស់ ក.ទ.ខ. ត្រូវបានជ្រើសតាំងដោយសហភាគរៈរបស់ខ្លួន និងទទួលស្គាល់ដោយ ក.ទ.ជ.។

សមាភាព ក.ទ.ជ. ក្នុងអណត្តិទី១ ត្រូវបានជ្រើសតាំង ដើម្បីដំណើរការអោយមានប្រសិទ្ធភាព ។

**មាត្រា ៣៩.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវតែងតាំងក្រុមការងារមួយជាបណ្តោះអាសន្ន ដើម្បីរៀបចំដំណើរការបង្កើតគណៈទន្តពេទ្យកម្ពុជា ។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**មាត្រា ៤០.-**

នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ២០០៥

**ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣រល.០៥០៩.៤១៧

**បានយកសេចក្តីក្រាបបង្គំទូលថ្វាយ**
**ព្រះមហាក្សត្រសូមឡាយព្រះហស្ថលេខា**
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខ: ១១៧៩ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ២០០៥
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**ងី តាយី**



13

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៥/៤៦០

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
## សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/0៧04/001 ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២004 ដែលប្រកាសអោយប្រើច្បាប់រដ្ឋធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២004 ស្តីពីការជ្រើសរើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានរដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

<u>មាត្រា ១</u>: **ត្រូវបានតែងតាំង :**

**ក : <u>ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី ១ រដ្ឋសភានីតិកាលទី ៣</u>**

១- ឯកឧត្តម **សរ សម្បត្តិ** ជាទីប្រឹក្សាមានឋានៈស្មើ រដ្ឋលេខាធិការ ។

២- ឯកឧត្តម **លឹម ថៃភាង** ជាទីប្រឹក្សាមានឋានៈស្មើ រដ្ឋលេខាធិការ ។

៣- ឯកឧត្តម **ម៉ែន ម៉ូនពិច** ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៤- ឯកឧត្តម **ពេជ្រ កៅ** ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៥- ឯកឧត្តម ស៊ឹម តែ ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៦- ឯកឧត្តម នង សាវ៉េត ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៧- ឯកឧត្តម សំ ប៊ុណ្ណារិន ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៨- ឯកឧត្តម នាង ផាន ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

៩- ឯកឧត្តម ទិត ប្រាក់ ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

១០-ឯកឧត្តម ហ៊ុន ម៉េងំរ ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

១១-ឯកឧត្តម ហង់ ឆូច ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

១២-ឯកឧត្តម ធាម លីមអៀង ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

១៣-ឯកឧត្តម ថន សាវ៉ាត ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

១៤-ឯកឧត្តម ណោ ណេង ជាទីប្រឹក្សាមានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

ខ: ជាជំនួយការ សម្តេច ហេង សំរិន អនុប្រធានទី ១ រដ្ឋសភានីតិកាលទី ៣

១៥-ឯកឧត្តម គីម ហេង ជាជំនួយការផ្ទាល់មានឋានៈស្មើ អគ្គនាយក ។

១៦-ឯកឧត្តម តាំង ហួត ជាជំនួយការផ្ទាល់មានឋានៈស្មើ អគ្គនាយក ។

១៧-ឯកឧត្តម តន់ គីមហុង ជាជំនួយការផ្ទាល់មានឋានៈស្មើ អគ្គនាយក ។

មាត្រា ២: ប្រធានរដ្ឋសភា និង នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់តាំងពីថ្ងៃឡាយព្រះហត្ថលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/០៩០៥/៤៣១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ ...១១០៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សុភារី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៥/៤១១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

( យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេច ហេង សំរិន ប្រធានរដ្ឋសភាស្តីទី )

តែងតាំង

ឯកឧត្តម អ៊ុំ ឆាយ

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៩.៤៣២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ ...៧៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ តាន់

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៥/៨១២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរជនា សម្ពោហាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានសំរួលភារកិច្ចឯកឧត្តម **ឡៃ វីរៈ** ឋាននន្តរសក្តិ ឧត្តមសេនីយ៍ទោ នៃក្របខ័ណ្ឌមន្ត្រីកងយោធពលខេមរភូមិន្ទ ពីអភិបាលខេត្ត ឧត្តរមានជ័យ អោយទៅបំរើការងារនៅក្រសួងការពារជាតិ ។

**មាត្រា ២ :** ត្រូវបានប្រគល់ភារកិច្ចជូនលោក **គុជ ម៉ូលី** មន្ត្រីក្របខ័ណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអភិបាលខេត្ត ឧត្តរមានជ័យ ដោយរក្សាឋាននន្តរសក្តិ និងថ្នាក់ដដែល ។

**មាត្រា ៣ :** លោក **គុជ ម៉ូលី** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

3/3

**មាត្រា ៤ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*នស/រកត.០៥០៩/៤៣៣*

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ២០០៥*

លេខ ...៧/២ ជ.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ីវ៉ាឌី តាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០៥/៤១៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងឯកឧត្តម សាយ លាងសេង ជាទីប្រឹក្សាសម្តេច នរោត្តម សិរីវុឌ្ឍ , ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ :** សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣៤.០៥០៩.៤៣៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០៥

លេខ ៣៩៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ២០

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

២៤

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៧៤០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ជូន *Mr. Jae-Youl Kim Ph.D., Secretary General of the Korea Foundation for Advanced Studies* ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការ រវាងរាជបណ្ឌិតសភាកម្ពុជា និង មូលនិធិកូរ៉េ សម្រាប់ការសិក្សាជាន់ខ្ពស់ ដោយបានជួយកសាងសមិទ្ធផលជាច្រើន នៅរាជបណ្ឌិតសភាកម្ពុជា ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៥

**នាយករដ្ឋមន្ត្រីស្តីទី**

**ស ខេង**

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Ps-216

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៥៧២.....សហវ.ពន

# ប្រកាស

## ស្តីពី

## ការប្រមូលពន្ធ អាករ ជាប្រាក់រៀល

## ទេសរដ្ឋមន្ត្រី

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៤/០០២ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ០៩៤ ប្រក.សហវ.ពដ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ ១៩៩៥ ស្តីពីការប្រមូលពន្ធឈ្នួលផ្ទះ និងដី និងពន្ធប៉ាតង់ជាប្រាក់ដុល្លាអាមេរិក
- បានឃើញសេចក្តីជូនដំណឹងលេខ ១២៧២ សជណ.សរ ចុះថ្ងៃទី០៥ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ។

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច ៖

**ប្រការ ១.-**

នាយកដ្ឋានពន្ធដារ និង គ្រប់អង្គភាពពន្ធដារទាំងអស់ ត្រូវធ្វើការប្រមូលពន្ធអាករគ្រប់ប្រភេទ ពីអ្នកជាប់ពន្ធជាប្រាក់រៀល ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ ៣.-**

ប្រកាសនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៥

**គាត ឈន់**

**ចម្លងជូន ៖**

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋានរដ្ឋសភា

ទីស្តីការគណៈរដ្ឋមន្ត្រី

គ្រប់ក្រសួង-រដ្ឋលេខាធិការដ្ឋាន

គ្រប់សាលាខេត្ត-ក្រុង

គ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

"ដើម្បីមុខការ"

ដូចប្រការ១ "ដើម្បីអនុវត្ត"

ឯកសារ-កាលប្បវត្តិ ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

គណៈកម្មការសុរិយោដីថ្នាក់ជាតិ

លេខ ១៤៥៥ ជនស/គសជ

# សេចក្តីណែនាំ
# ស្តីពី
# នីតិវិធីសវនាការ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ

អនុលោមតាមអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការកំណត់អំពីនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ដូចតទៅ :

## I.ការចាប់ផ្តើមនៃករណីវិវាទ

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិទទួលករណីវិវាទពីគណៈកម្មការសុរិយោដីខេត្ត ក្រុង និងគណៈកម្មការរដ្ឋបាលដែលធ្វើការសម្រុះសម្រួលមិនបានជោគជ័យ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវរៀបចំទម្រង់បែបបទបញ្ជាក់ពីការទទួលសំណុំរឿងវិវាទដែលបានបញ្ជូនមក ហើយទំរង់បែបបទនេះត្រូវបានរក្សាទុកក្នុងសំណុំរឿងវិវាទ ។ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវចុះលេខសំណុំរឿងវិវាទ ។

២-លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ពិនិត្យមើលឡើងវិញនូវសំណុំរឿងវិវាទផ្លូវការ ហើយធ្វើកំណត់បង្ហាញឱ្យបានឆាប់បំផុតជូនទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ កំណត់បង្ហាញនេះធ្វើការសំគាល់ថា តើសំណុំរឿងវិវាទមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ឬទេ ហើយថាតើត្រូវឱ្យមានការស៊ើបអង្កេតបន្ថែមដែរ ឬទេ ។

៣-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ប្រសិនបើយល់ថាជាការចាំបាច់ ។ នៅដំណាក់កាលណាមួយនៃដំណើរការវិនិច្ឆ័យមុននឹងធ្វើសេចក្តីសំរេច គណៈកម្មការ

សុរិយោដីថ្នាក់ជាតិអាចបង្គាប់ឱ្យមានការស៊ើបអង្កេតបន្ថែមទៀតបាន ។ ការស៊ើបអង្កេតនេះគឺត្រូវធ្វើឡើងដោយលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើការបង្គាប់ផ្សេងទៀតដែលចាំបាច់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីរៀបចំសំណុំរឿងវិវាទឱ្យមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ។

## II.ការរៀបចំដំណើរការករណីវិវាទ

នៅពេលសំណុំរឿងវិវាទមានលក្ខណៈពេញលេញនិងគ្រប់គ្រាន់ហើយនោះ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបញ្ជូនសំណុំរឿងនេះទៅប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដើម្បីធ្វើការពិនិត្យ ។ ក្រោយពីការពិនិត្យរួច ហើយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចកំណត់ ÷

១-ចំពោះសំណុំរឿងវិវាទដែលចាំបាច់ត្រូវមានការពិភាក្សាផ្ទៃក្នុង ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចអញ្ជើញសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ លេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ និងសមាជិកអាដហុក (សមាជិកចំពោះកិច្ច) ចូលរួម ។ ការពិភាក្សាផ្ទៃក្នុងនេះជាការពិគ្រោះយោបល់ដើម្បីសំរេចបន្តករណីវិវាទ ឬ ត្រូវប្រានចោលករណីវិវាទតែប៉ុណ្ណោះ ដោយពុំចាំបាច់មានការជូនដំណឹងដល់សាធារណៈជន និងប្រពន្ធ័ផ្សព្វផ្សាយឡើយ ។

២-ចំពោះសំណុំរឿងវិវាទដែលមានពាក្យបណ្តឹងមិនត្រឹមត្រូវឬគ្មានមូលដ្ឋាន ដែលធ្វើឡើងគ្រាន់តែដើម្បីយាយីឬបំភិតបំភ័យភាគីវិវាទម្ខាង ឬមិនស្ថិតក្នុងយុត្តាធិការរបស់គណៈកម្មការសុរិយោដី ទោះស្ថិតក្នុងដំណាក់កាលកំពុងដំណើរការក្នុងនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិក៏ដោយ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសំរេចប្រានចោលសំណុំរឿងវិវាទនោះ ។

៣-ចំពោះសំណុំរឿងវិវាទដែលមានលក្ខណៈពេញលេញ និងគ្រប់គ្រាន់ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិអាចបង្គាប់ទៅលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដើម្បីកំណត់អំពីទីកន្លែង និងពេលវេលាដែលនឹងត្រូវរៀបចំសវនាការនៃសំណុំរឿងវិវាទនោះ ។ បន្ទាប់ពីបានទទួលរបាយការណ៍អំពីពេលវេលានិងទីកន្លែងច្បាស់លាស់ដែលត្រូវរៀបចំសវនាការ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវសំរេចបើកសវនាការលើសំណុំរឿងវិវាទនេះ ។

៤-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចបង្គាប់ឱ្យមានការសម្រុះសម្រួលវិវាទបន្ថែមទៀតតាមសំណើរបស់ភាគីវិវាទ ឬតាមការយល់ឃើញរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ នីតិវិធីរដ្ឋបាលនៃការសម្រុះ-សម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវអនុវត្តដូចនីតិវិធីទាំងឡាយសំរាប់គណៈកម្មការសុរិយោដីស្រុក ខណ្ឌដែរ ។ នៅពេលដំណើរការនីតិវិធីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ ភាគីវិវាទអាចបដិសេធការចូលរួមរបស់ប្រធាន ឬ សមាជិក រូបណាដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ ។ ប្រធាន ឬសមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលពាក់ព័ន្ធនឹងវិវាទផលប្រយោជន៍ត្រូវដកខ្លួនចេញពីការដោះស្រាយករណីវិវាទនោះ ហើយរដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវតែងតាំងប្រធានអាដហុក (ប្រធានចំពោះកិច្ច) ឬសមាជិកថ្មីជំនួសវិញ ។ ក្នុងកំលុងពេលនៃដំណើរការនីតិវិធីរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិរហូតដល់ពេលធ្វើសេចក្តីសំរេចលើវិវាទ ភាគីវិវាទនីមួយៗ ឬ តំណាងអាចផ្តល់ឯកសារជា ភស្តុតាង ឬសាក្សីបន្ថែមទៀតក្រៅពីភស្តុតាង និងសាក្សីដែលបានផ្តល់ពីពេលមុន ។

## III. ការជូនដំណឹង និងពេលវេលានៃសវនាការ

### ក-ការជូនដំណឹង

ការជូនដំណឹងអំពីសវនាការត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយកំណត់ច្បាស់លាស់ អំពីកាលបរិច្ឆេទ និងទីកន្លែងដែលត្រូវបើកសវនាការ ។ លិខិតជូនដំណឹងត្រូវប្រគល់ឱ្យដល់ដៃដើមបណ្តឹង ឬតំណាង និង ចុងបណ្តឹង ឬ តំណាង យ៉ាងហោច ១៥ថ្ងៃ នៃថ្ងៃធ្វើការ មុនថ្ងៃបើកសវនាការ ដោយមានហត្ថលេខា ឬស្នាមមេដៃរបស់អ្នកទទួល និងអ្នកប្រគល់លិខិតជូនដំណឹងនោះ ។ ក្នុងករណីភាគីវិវាទណាមួយបដិសេធមិនទទួល ឬ អវត្តមានពីលំនៅដ្ឋានដោយគ្មានមូលហេតុសមស្រប អ្នកប្រគល់លិខិតត្រូវចារលើខ្នងលិខិតបញ្ជាក់ពីមូលហេតុ។

### ខ-ពេលវេលាសវនាការ

គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវបើកសវនាការចាប់ពីម៉ោង ០៨ : ៣០នាទី ព្រឹក ដល់ម៉ោង ១១ : ៣០ នាទីនៃថ្ងៃធ្វើការ ។ ក្នុងករណីចាំបាច់សវនាការអាចធ្វើនៅម៉ោងផ្សេងពីការកំណត់នេះ ឬអាចបន្តទៅទៀតបាន ។ ការបើកសវនាការអាចដោះស្រាយបណ្តឹងច្រើនករណីបាន ។

### គ-ការបង្ហាញខ្លួននៅពេលសវនាការ

១-ប្រសិនបើភាគីដើមបណ្តឹង ឬ តំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវចេញសេចក្តីសំរេចបញ្ជាក់ពីការបញ្ឈប់ដំណើរការដោះស្រាយ ។

២-ប្រសិនបើភាគីចុងបណ្តឹង ឬតំណាង បានទទួលលិខិតជូនដំណឹងហើយ តែមិនបានមកបង្ហាញខ្លួននៅថ្ងៃសវនាការដោយគ្មានមូលហេតុ ឬ មានមូលហេតុមិនសមស្រប ប្រធានសវនាការត្រូវសំរេចករណីវិវាទនេះដោយអវត្តមានចុងបណ្តឹង ឬតំណាង។

៣-បើភាគីដើមបណ្តឹង ឬ/នឹងចុងបណ្តឹង ស្លាប់មុនពេលសវនាការ អ្នកតំណាងស្របច្បាប់របស់ភាគីនោះអាចចូលរួមក្នុងសវនាការបាន ។

៤-សាក្សីគ្រប់រូបត្រូវមកបង្ហាញខ្លួនចំពោះមុខប្រធានសវនាការតាមការអញ្ជើញ ។

## IV. អំពីសវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ គឺជាដំណើរការនៃការប្រជុំរវាងភាគីវិវាទ ( ឬតំណាង ) និងសាក្សី ជាមួយនឹងក្រុមវិនិច្ឆ័យ ឬប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬសមាជិកតែម្នាក់ ឬ មន្ត្រីសវនាការ ដែលរៀបចំឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីសំរេចទទួលស្គាល់ភោគីស្របច្បាប់ចំពោះដីវិវាទដែលមិនទាន់ចុះបញ្ជីសុរិយោដី ។ សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិត្រូវធ្វើឡើងជាសាធារណៈ ។

សវនាការរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចដឹកនាំដោយ :

-ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ តែ១ រូប ជាប្រធានសវនាការ ឬ

-សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-មន្ត្រីសវនាការតែ ០១ រូប ដែលត្រូវបានតែងតាំងជាប្រធានសវនាការ ឬ

-ក្រុមវិនិច្ឆ័យមានសមាសភាព ប្រធាន និងសមាជិកមួយរូប ឬសមាជិកទាំងអស់ នៃគណៈកម្មការសុរិយោដីថ្នាក់ជាតិ ដែលដឹកនាំដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ជាប្រធានក្រុមវិនិច្ឆ័យ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចរៀបចំឱ្យមានជាសវនាការចល័ត ឬ អចល័ត :

**- <u>សវនាការចល័ត</u>**

ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ អាចសំរេចឱ្យមានការធ្វើសវនាការចល័តតាមសំណូមពររបស់ភាគីវិវាទបាន ។ សវនាការចល័តត្រូវធ្វើឡើងនៅលើ ឬជិតទីតាំងដីទំនាស់ ឬកន្លែងណាមួយដែលភាគីវិវាទសំណូមពរ សវនាការចល័តអាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

**-សវនាការអចល័ត**

សវនាការអចល័តធ្វើឡើងដោយការសំរេចរបស់ប្រធានគណៈកម្មការថ្នាក់ជាតិ ឬ/និងតាមសំណូមពររបស់ភាគីវិវាទ ។ សវនាការអចល័តត្រូវធ្វើនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។ សវនាការអចល័ត អាចដឹកនាំដោយក្រុមអ្នកវិនិច្ឆ័យ ឬសមាជិកគណៈកម្មការតែម្នាក់ ឬមន្ត្រីសវនាការតែមួយរូបដែលតែងតាំងជាប្រធានសវនាការ ។

គណៈកម្មការសុរិយោដីថ្នាក់ជាតិ ត្រូវបើកសវនាការរបស់ខ្លួន តាមរបៀបដូចខាងក្រោមៈ

១-គណៈកម្មការសុរិយោដីថ្នាក់ជាតិអាចធ្វើសវនាការជាក្រុមវិនិច្ឆ័យ ឬ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិតែម្នាក់ ឬ មន្ត្រីសវនាការតែ១រូប ដែលតែងតាំងជាប្រធានសវនាការ ។

២-សវនាការត្រូវប្រព្រឹត្តទៅក្រោមការដឹកនាំរបស់ប្រធានសវនាការ ។ ប្រធានសវនាការអាចជាប្រធាន ឬ សមាជិកគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬមន្ត្រីសវនាការ ដែលចាត់តាំងដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

៣-ក្នុងពេលសវនាការ ប្រធានសវនាការ ត្រូវមានលេខាធិការសវនាការជាជំនួយការ ដែលជាមន្ត្រីលេខាធិការដ្ឋានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។

## V. ដំណើរការនៃការរៀបចំសវនាការ

របៀបរៀបចំសវនាការត្រូវធ្វើតាមការណែនាំដូចខាងក្រោម :

**ក-លេខាធិការសវនាការ**

លេខាធិការសវនាការមានភារៈកិច្ចដូចតទៅ ÷

-ពិនិត្យ ឬស្រង់វត្តមាន អវត្តមានដើមបណ្តឹង ចុងបណ្តឹង ឬតំណាង និងសាក្សី

-អានបទបញ្ជាផ្ទៃក្នុងនៃសវនាការ

-នាំភាគីវិវាទ និងសាក្សីទៅស្បថ

-ប្រាប់ទៅអ្នកចូលរួមទាំងអស់ឱ្យក្រោកឈរនៅពេលលេខាធិការសវនាការស្រែកថា "ប្រធានសវនាការ"

-រាយការណ៍ពី វត្តមាន អវត្តមាន អំពីភាគីវិវាទពាក់ព័ន្ធ ជូនប្រធានសវនាការ

-រាយការណ៍ដោយសង្ខេបនូវដំណើររឿងរបស់ករណីវិវាទ

-ត្រូវសរសេរ ឬកត់ត្រាកំណត់ហេតុសវនាការ ។ កំណត់ហេតុសវនាការត្រូវមានហត្ថលេខាអ្នកកត់ត្រា ភាគីវិវាទ និង សាក្សី ។

-អានឯកសារផ្សេងៗដែលពាក់ព័ន្ធតាមការស្នើសុំពីប្រធានសវនាការ ។

**ខ-ប្រធានសវនាការ**

-ប្រធានសវនាការត្រូវអង្គុយតាមកន្លែងដែលបានរៀបចំទុក ។

-ប្រធានសវនាការអង្គុយចំកណ្តាល

-សមាជិកអង្គុយអមសងខាង

-លេខាធិការសវនាការត្រូវអង្គុយនៅតុផ្សេងដែលស្ថិតនៅខាងស្តាំដៃប្រធានសវនាការ

ក្រោយពីបានអង្គុយតាមកន្លែងកំណត់រួចមកប្រធានសវនាការត្រូវប្រកាសថា " យើងសូមបើកសវនាការ " រួចត្រូវបន្តសេចក្តីតាមលំដាប់ដូចតទៅ ÷

១-សវនាការនេះត្រូវបានធ្វើឡើងដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងមូល ឬដោយប្រធានគណៈកម្មការសុរិយោដីថ្នាក់ជាតិ ឬ ដោយសមាជិកតែម្នាក់ ឬដោយមន្ត្រីសវនាការតែមួយរូប ដោយបង្ហាញអំពីឈ្មោះ និងឋានៈរបស់ប្រធានសវនាការ ឬ/និង សមាជិកសវនាការ ព្រមទាំងលេខាធិការសវនាការ លេខសំណុំរឿងករណីវិវាទ ឈ្មោះភាគីវិវាទ ទីតាំងដីវិវាទ និងកម្មវត្ថុនៃវិវាទ ។

